# សារលិខិត
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងឱកាសទិវាសន្តិភាពអន្តរជាតិ
# ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២

សូមថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ

**ជនរួមជាតិជាទីស្នេហា!**

ក្នុងបុព្វហេតុ ទប់ស្កាត់ និងបញ្ឈប់ជម្លោះប្រដាប់អាវុធ និងសង្គ្រាមនៅគ្រប់ទីកន្លែងទូទាំងពិភពលោក អង្គការសហប្រជាជាតិបានកំណត់យកថ្ងៃទី២១ ខែកញ្ញា រៀងរាល់ឆ្នាំ ជាកាលបរិច្ឆេទសម្រាប់ប្រារព្ធ **«ទិវាសន្តិភាពអន្តរជាតិ»**។ ក្រោមមូលបទ **«បញ្ចប់ការរើសអើងជាតិសាសន៍ និងកសាងសន្តិភាព»** ការអបអរសាទរ **«ទិវាសន្តិភាពអន្តរជាតិ»** ឆ្នាំនេះ ផ្តោតលើការពង្រឹងសាមគ្គីភាពអន្តរជាតិ ការថែរក្សា និងលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលសុខសម្រាប់មនុស្សជាតិ។

តាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ សូមសម្តែងអំណរសាទរ និងចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងការប្រារព្ធ **«ទិវាសន្តិភាពអន្តរជាតិ»** ដ៏មហោឡារិកនេះ ដើម្បីរំលេចអត្ថន័យដ៏ថ្លៃថ្លានៃសន្តិភាព ក៏ដូចជាឆ្លុះបញ្ចាំងនូវឆន្ទៈដ៏មោះមុតរបស់ប្រជាជនកម្ពុជា ក្នុងការការពារ និងចូលរួមកសាងសន្តិភាពសកល។

**ជនរួមជាតិជាទីស្នេហា!**

ក្រោយឆ្លងកាត់ភ្លើងសង្គ្រាម និងសោកនាដកម្មអស់ជាងពីរទសវត្សរ៍ កម្ពុជាទទួលបានបទពិសោធន៍ និងមេរៀនដ៏ជូរចត់ ដែលនាំឱ្យយើងយល់ច្បាស់ពីតម្លៃនៃសន្តិភាព និងស្ថិរភាព។ បន្ទាប់ពីទទួលបានឯករាជ្យនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ប្រជាជនកម្ពុជាបានរស់ក្នុងសុខសន្តិភាព និងការអភិវឌ្ឍ ត្រឹមតែប្រមាណ១៧ ឆ្នាំប៉ុណ្ណោះ ក៏ត្រូវហែលឆ្លងទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់ខ្លួន បន្ទាប់ពីរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ដែលបានរុញច្រានកម្ពុជាឱ្យចូលក្នុងភ្នក់ភ្លើងសង្គ្រាមស៊ីវិល និងរាលពិឃាតក្នុងរបបប្រល័យពូជសាសន៍។ ក្រោយការផ្តួលរំលំនៃរបបខ្មៅងងឹតនេះនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជា ខំប្រឹងកសាងប្រទេសជាតិពីផេះផង់នៃសង្គ្រាម និងវិនាសកម្មក្នុងថ្លុកឈាមបណ្តើរ ខំទប់ស្កាត់ការវិលមកវិញនូវរបបពិឃាតបណ្តើរ។ មិនត្រឹមប៉ុណ្ណោះ ប្រជាជនកម្ពុជា ថែមទាំងត្រូវដោះស្រាយវិបត្តិសេដ្ឋកិច្ច-សង្គម ដែលបណ្តាលមកពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងការបិទខ្ទប់ពាណិជ្ជកម្មអស់រយៈពេលជាង ១២ ឆ្នាំ។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងវត្តមានរបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) រហូតដល់ឆ្នាំ១៩៩៣ ពិតជាបានចូលរួមចំណែកត្រួសត្រាយផ្លូវសម្រាប់ការស្វែងរកសន្តិភាពនៅកម្ពុជា តែពុំបានបញ្ចប់សង្គ្រាមជាស្ថាពរនោះទេ។ ប្រជាជនកម្ពុជា បានទទួលសន្តិភាពទាំងស្រុងនៅឆ្នាំ ១៩៩៨ តាមរយៈ «នយោបាយឈ្នះ-ឈ្នះ» ដែលខ្ញុំព្រះករុណា បានផ្តួចផ្តើម និងដាក់ចេញ។ ក្រោមម្លប់សន្តិភាព និងការបង្រួបបង្រួមជាតិនេះ រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា បានខិតខំស្តារ និងកសាងប្រទេសជាតិឡើងវិញ ដោយទទួលបានការរីកចម្រើនលើគ្រប់វិស័យគួរជាទីមោទនៈ។ ជាក់ស្តែង កម្ពុជាបានចេញផុតពីប្រទេសមានចំណូលទាប ទៅជាប្រទេសចំណូលមធ្យមកម្រិតទាប ហើយកំពុងខិតខំពុះពារសម្រេចឱ្យបានតាមចក្ខុវិស័យអភិវឌ្ឍ ដើម្បីប្រែក្លាយខ្លួនទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

នាពេលថ្មីៗនេះ កម្ពុជាទទួលបាននូវភាពជោគជ័យយ៉ាងត្រចះត្រចង់ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ ដោយសារតែការអនុវត្តគោលនយោបាយមានប្រសិទ្ធភាព ទាន់ពេលវេលា និងចំទិសដៅ ជាពិសេស «យុទ្ធនាការស្រោចវ៉ាក់សាំង» ទូទាំងប្រទេសដោយពុំគិតថ្លៃ។ មកដល់ពេលនេះ ប្រជាពលរដ្ឋ និងប្រជាជនគ្រប់ជាតិសាសន៍ទាំងអស់ ដែលកំពុងស្នាក់នៅ និងបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជាចំនួនជិត ៩៥% ទទួលបានការចាក់វ៉ាក់សាំងគ្រប់ដូស។ ការណ៍នេះ បានអនុញ្ញាតឱ្យកម្ពុជាចាប់ផ្តើមស្តារសេដ្ឋកិច្ច-សង្គម និងបើកប្រទេសឡើងវិញ។ នៅក្នុងឆ្នាំ២០២២នេះ កម្ពុជារំពឹងថានឹងមានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៥,៤% ជាមួយនឹងអត្រាអតិផរណាប្រមាណ ៥% ទោះបីជាសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែនបាននិងកំពុងបង្កផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោក និងតំបន់ក៏ដោយ។ ដោយសារភាពជោគជ័យទាំងនេះ កម្ពុជាទទួលបានចំណាត់ថ្នាក់លេខ១ ក្នុងចំណោម ១២១ ប្រទេស ដែលកំពុងស្តារសេដ្ឋកិច្ច-សង្គមក្រោយជំងឺកូវីដ-១៩។

ជនរួមជាតិជាទីស្នេហា!

ក្នុងស្មារតីលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាព កម្ពុជាបាននិងកំពុងចូលរួមយ៉ាងសកម្មជាមួយគ្រប់ប្រទេសទាំងអស់នៅក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ។ ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២នេះ កម្ពុជាបាននិងកំពុងដឹកនាំអាស៊ានឆ្លងកាត់បញ្ហាប្រឈមធំៗព្រមគ្នាដ៏ច្រើនមិនធ្លាប់មានពីមុនមក។ ក្នុងបរិបទនេះ កម្ពុជាបានកំណត់យកមូលបទ៖ "អាស៊ានរួមគ្នាធ្វើ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា" ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមខាងលើ ព្រមទាំងបន្តកសាងសហគមន៍អាស៊ាន លើកកម្ពស់មជ្ឈអាស៊ានក្នុងការកសាងនិម្មាបនកម្មតំបន់ និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា សំដៅរួមចំណែកថែរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុង និងក្រៅតំបន់អាស៊ាន។

ដោយសារសន្តិភាព ការរួបរួមជាធ្លុងមួយ និងសុខដុមនីយកម្មរវាងប្រទេសជាសមាជិកអាស៊ានជាមូលដ្ឋានដ៏មានសារៈសំខាន់ជាសារវន្ត កម្ពុជាបានប្រឹងប្រែងជួយស្វែងរកដំណោះស្រាយវិបត្តិមីយ៉ាន់ម៉ាដោយផ្អែកលើអភិក្រមជាក់ស្តែងនិយម តាមរយៈការអនុវត្តតាមកិច្ចព្រម

ព្រៀងជាឯកច្ឆន្ទ ៥ ចំណុច របស់អាស៊ាន ដើម្បីជួយឱ្យមីយ៉ាន់ម៉ាវិលទៅរកប្រក្រតីភាពឡើងវិញ ក៏ដូចជាអនុញ្ញាតឱ្យអាស៊ានវិលត្រឡប់ទៅរកការរួបរួមរវាងសមាជិកទាំង ១០ វិញ ។

ក្រោមឆត្ររបស់អង្គការសហប្រជាជាតិ កម្ពុជាបាននិងកំពុងចូលរួមចំណែកយ៉ាងសកម្ម ក្នុងកិច្ចសហប្រតិបត្តិការថែរក្សាសន្តិភាពពិភពលោក។ ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២២ កម្ពុជា បានបញ្ជូនកងកម្លាំងសរុបចំនួន ៨,៣០២នាក់ (ក្នុងនោះ ស្ត្រី៥៨០នាក់) ទៅបំពេញបេសកកម្ម ថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិក្នុងប្រទេសចំនួន០៩ រួមមាន៖ ឆាដ ស៊ូដង់ ស៊ូដង់ ខាងត្បូង អាហ្វ្រិកកណ្តាល លីបង់ ស៊ីប ស៊ីរី ម៉ាលី និងយេម៉ែន។ បច្ចុប្បន្ននេះ កងកម្លាំងកម្ពុជាសរុប ចំនួន ៨០១នាក់ (ក្នុងនោះស្ត្រី១១៨នាក់) កំពុងបំពេញបេសកកម្មថែរក្សាសន្តិភាពនៅប្រទេស ស៊ូដង់ខាងត្បូង លីបង់ ម៉ាលី អាហ្វ្រិកកណ្តាល និងយេម៉ែន។

**ជនរួមជាតិជាទីស្នេហា!**

ខ្ញុំព្រះករុណាខ្ញុំ មានជំនឿយ៉ាងមុតមាំថា ពិធីអបអរសារទរ «**ទិវាសន្តិភាពអន្តរជាតិ**» ឆ្នាំនេះ ស្តែងឱ្យឃើញកាន់តែច្បាស់អំពីឆន្ទៈ និងការប្តេជ្ញាចិត្តកាន់តែក្លៀវក្លា របស់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកកម្ពស់តម្លៃនៃសន្តិភាព កិច្ចសហប្រតិបត្តិការ និងការគោរពគ្នា ទៅវិញទៅមក ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ និងសាសនា សំដៅកសាងពិភពលោក មួយ ប្រកបដោយសន្តិសហវិជ្ជមាន ភាពធន់ និងការអភិវឌ្ឍដោយបរិយាប័ន្ន និងចីរភាព។

ជាកិច្ចបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រសិទ្ធពរជូនដល់ជនរួមជាតិជាទីស្នេហា សូមចៀសផុត ពីជំងឺឆ្លងនានា និងសូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ។

ជយោ! សន្តិភាព និងសូមអរគុណ សន្តិភាព៕

ថ្ងៃទី ចន្ទ ៩ រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០២២

**ហ៊ុន សែន**